Tome VII

"Kambujasuriya"

INDOCHINE FRANÇAISE
RÉGIE DU DÉPÔT LÉGAL

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

INSTITUT BOUDDHIQUE

Juillet n° 7

ឆ្នាំទី ២៥ ខែកក្កដា លេខ ៧

ព.ស. ២៤៩៦ – គ.ស. ១៩៥៣

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ


| ផ្នែកសាសនា | បញ្ជីរឿង | ទំព័រ |
|---|---|---|
| — សង្គហធម៌ ................ | ព្រះបាឡាត់ឧត្តមលិខិត សុង-ស៊ីវ | ៤៨៣ |
| — កឋិនកថា (តមក) ............ | ព្រះមហាឧត្តមវិជ្ជា កែ - អឿន .. | ៤៩៨ |
| — ប្រវត្តិព្រះអភិធម្ម ............ | ឃុនសិរីមេធី ស៊ី- អ៊ូ ....... | ៥០៥ |
| **ផ្នែកអក្សរសាស្ត្រ** | | |
| — ការបណ្ដុះនិស្ស័យ (តមក) ....... | ព្រះមហាឧត្តមវិជ្ជា ប៊ុង - ប៉ម ... | ៥០៨ |
| — រឿងសាមកុក (តមក) .......... | ឧកញ៉ា នូ - កន .......... | ៥១៥ |
| — រឿងអារ័ក្សថ្លែងរឿងម្ភៃប្រាំ (តមក) ... | លោក ហ៊ាយ - ប៊ុក ......... | ៥២៤ |
| — រឿងបិញ្ចៀនទិព្វ (តមក) .......... | អ្នកស្រីសារីយ៉ាន់ ......... | ៥៣៣ |
| — រឿងប៉ូលនិងវីរ័ស៊ីនី (តមក) ....... | លោក ផេង - ជ្រីវ ......... | ៥៣៩ |
| — សកម្មភាពនៃក្រុមជំនុំទំនៀមទម្លាប់ខ្មែរ (ល្បែងទាញព្រ័ត្រ) ............ | លោក ជាប- ពិន. ....... | ៥៤៤ |
| — ទិដ្ឋានុគតិ .................. | លោក ផៃន - វិន ក្រសួងបឋមសិក្សា សៀមរាប ..... | ៥៥១ |
| **កំណត់និងប្រវត្តិការណ៍** | | |
| — សុន្ទរកថាបណ្ឌិតម៉ាល៉ាល៉ះសេកេរៈថ្លែងក្នុងសមាជសាកលលើកទី ២ នៃពុទ្ធសាសនា (តមក) | ពុទ្ធសាសនបណ្ឌិត្យ... | ៥៥៦ |



មួយឆ្នាំមាន ១២ សៀវភៅ — ដំឡៃជាវ ១៩២រ. ០០

## សង្គហធម៌

### ព្រះបាឡាត់ឧត្តមលិខិត សុង-ស៊ីវ វត្តលង្កា ភ្នំពេញ

ទេសនាផ្សាយវិទ្យុប្រទេសកម្ពុជា កាលពីថ្ងៃ ៩ កើត ខែផល្គុន ឆ្នាំជូតសំរិទ្ធិស័ក

ព.ស. ២៤៩១ (២២-៣-៤៩)

---

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

វេលានេះ អាត្មាភាពសូមសំដែង អំពីសង្គហធម៌ ដែលមានក្នុង សុត្តន្តបិដក គម្ពីរទីឃនិកាយ បាដិកវគ្គ ដូចសេចក្តីតទៅនេះ:-

កិច្ចឬឧបាយសម្រាប់សង្គ្រោះ ឬក៏ស្រោចស្រង់គ្នានឹងគ្នាឲ្យមានក្តីស្នេហាទៅវិញទៅមក កុំឲ្យបែកបាក់គ្នា ហៅថា សង្គហធម៌ (ឬជា បិយករណធម៌ ជាគ្រឿងធ្វើនូវសេចក្តីស្រឡាញ់), មាន ៤ យ៉ាង ដូចពុទ្ធភាសិតមួយកន្លែង ក្នុងសិង្គាលោវាទសូត្រថា:-

ទានញ្ច បិយវជ្ជញ្ច     អត្ថចរិយា ច យា ឥធ
សមានត្តតា ច ធម្មេសុ   តត្ថ តត្ថ យថារហំ
ឯតេ ខោ សង្គហា លោកេ រថស្សាណីវ យាយតោ
ឯតេ ច សង្គហា នាស្សុ ន មាតា បុត្តការណា
លភេថ មានំ បូជំ វា     បិតា វា បុត្តការណា ។

សេចក្តីថា: ធម៌សម្រាប់សង្គ្រោះមនុស្សក្នុងលោកនេះ មាន ៤ យ៉ាង គឺ: ការឲ្យទាន ១, ពោលពាក្យពីរោះ ១, កិរិយាប្រព្រឹត្តិអំពើ

ឲ្យជាប្រយោជន៍ ១, ភាពជាអ្នកតាំងខ្លួនឲ្យស្មោះស្មើ ១, ធម៌ទាំងប៉ុណ្ណោះនេះ រមែងប្រព្រឹត្តទៅក្នុងលោកដូចកែបកង់នៃរទេះ ។ អធិប្បាយថា រទេះកាលបើមានកែបកង់ ទើបអាចប្រព្រឹត្តទៅ បើមិនមានទេក៏មិនអាចប្រព្រឹត្តទៅបានឡើយ ដូចម្ដេចមិញ, សត្វលោក កាលបើមានសង្គហធម៌ទាំង ៤ នេះ ទើបប្រព្រឹត្តទៅបាន បើមិនមានទេក៏មិនអាចប្រព្រឹត្តទៅបានដូច្នោះឯង ។ បើសង្គហធម៌ប៉ុណ្ណោះមិនមានហើយ មាតាក្ដី បិតាក្ដី ក៏មិនបាននូវការបូជា ឬសេចក្ដីរាប់អានអំពីបុត្ររបស់ខ្លួនឡើយ ។

១.— ការឲ្យទាន.— ទាននោះចែកចេញជា ២ យ៉ាង គឺ: សាធារណទាន ១ អសាធារណទាន ១ ។ ឲ្យចំពោះរូបបុគ្គលម្នាក់ៗ ដូចជាមាតាបិតាឲ្យអាហារ, ឲ្យគ្រឿងប្រដាប់ស្លៀកពាក់, ឲ្យទ្រព្យសម្បត្តិធ្វើដើមទុនដល់បុត្រធីតា ឬក៏បុត្រធីតាដែលមានផ្ទះសម្បែងហើយ បានជូនភោជនាហារគ្រឿងស្លៀកពាក់ដល់មាតាបិតាដែលចាស់ជរា, យ៉ាងនេះហៅថា អសាធារណទាន ។ ឥស្សរជន ឬអ្នកមានទ្រព្យសម្បត្តិជាអ្នកមានចិត្តសប្បាយមេត្តា អាណិតអាសូរដល់មហាជនហើយលះបង់ទ្រព្យសម្បត្តិ ជួលគេឲ្យលើកថ្នល់, ជីកព្រែក, ធ្វើស្ពាន ដើម្បីជាផ្លូវគមនាគមន៍ទៅមកបានស្រួល ឬដាំដើមឈើ, ជីកស្រះ, ជីកអណ្ដូង, សង់សាលាដើម្បីជាទីសំណាក់អាស្រ័យដល់មនុស្សអាគន្តុកៈ ឬទំនុកបំរុងធ្វើផ្ទះពេទ្យ, សាលាបង្រៀនជាទីឲ្យចំណេះវិជ្ជាដល់កុមារកុមារី,

យ៉ាងនេះហៅថា សាធារណទាន ព្រោះឲ្យមិនចំពោះរូបបុគ្គលម្នាក់ៗ; នេះជាសង្គហធម៌ទី ១ ។

២.— ការពោលពាក្យពីរោះ នោះអធិប្បាយថា អ្នកឲ្យបើ គ្រាន់តែឲ្យប៉ុណ្ណោះ ប៉ុន្តែមិនបានពោលពាក្យពីរោះគួរឲ្យជាប់ចិត្តផងទេ, វត្ថុដែលឲ្យនោះ បើទុកជាច្រើនយ៉ាងណា ក៏ប្រាកដហាក់ដូចជាតិច, បើពោលពាក្យពីរោះគួរឲ្យជាប់ចិត្តផង, ក៏វត្ថុដែលឲ្យនោះសូម្បីតិចតួច នោះក៏ប្រាកដហាក់ដូចជាច្រើន ព្រោះធ្វើឲ្យកើតសេចក្ដីស្រឡាញ់ពេញចិត្ត, ដូចភាសិតបុរាណថា: "ប្រហុកអំបិលក៏ដោយចុះឲ្យតែបានគណ្ដាប់មាស"; ព្រោះហេតុនោះ បានជាព្រះសម្ពុទ្ធជាម្ចាស់ទ្រង់ចាត់ការពោលពាក្យពីរោះ ថាជាសង្គហធម៌ទី ២ ។

៣.— កិរិយាប្រព្រឹត្តអំពើឲ្យជាប្រយោជន៍ អធិប្បាយថា អ្នកឲ្យបើប្រសិនជាឲ្យហើយនិយាយពីរោះផង ដែលជាគុណជាប់ចិត្តចងមេត្រីទុកបានយ៉ាងស្និទ្ធហើយ, ប៉ុន្តែបើជាមនុស្សចេះតែមើលបំណាំគ្នាទៅវិញទៅមក មិនប្រព្រឹត្តប្រយោជន៍ដល់គ្នានឹងគ្នា គឺថាមិនហុចប្រយោជន៍ឲ្យ មិនប្រាប់ឧបាយឲ្យកើតប្រយោជន៍ គ្រាន់តែឲ្យរបស់ និងនិយាយពីរោះប៉ុណ្ណោះ ការស្និទ្ធនោះក៏នឹងសាបសូន្យទៅវិញដោយឆាយ ៗ ព្រោះហេតុនោះ ការប្រព្រឹត្តអំពើជាប្រយោជន៍នេះ ចាត់ជាសង្គហធម៌ទី ៣ ។

៤.— ភាពជាអ្នកតាំងខ្លួនឲ្យស្មោះស្មើ នោះអធិប្បាយថា អ្នកឲ្យស៊ូម្បីឲ្យហើយ និយាយពាក្យពីរោះ ព្រមទាំងជួយខ្វល់ខ្វាយធ្វើប្រយោជន៍ឲ្យដល់គ្នានឹងគ្នាហើយ តែបើមិនចេះរៀបចំខ្លួនឲ្យសមតាមយសសក្តិ ឬមិនស្គាល់ធំ, តូច, ខ្ពស់ ទាប ជាអ្នកប្រកាន់មានះមើលងាយគេ; សេចក្តីរាប់អានគ្នាក៏នឹងសាបសូន្យទៅវិញ ។ លុះតែអាស្រ័យនូវសេចក្តីស្មោះស្មើ តាំងខ្លួនឲ្យសមតាមយសសក្តិផង, ទើបសេចក្តីរាប់អាននោះនឹងមានកំឡាំងភាពតាំងនៅយូរអង្វែងទៅបាន ។ នេះរាប់ជាសង្គហធម៌គំរប់ ៤ ។

សព្វសត្វទាំងអស់ក្នុងលោកគួរមានសង្គហធម៌ សង្គ្រោះដល់គ្នានឹងគ្នាទៅវិញទៅមកតាមឋានតាមថ្នាក់ ទើបចក្រទាំងគូ គឺពុទ្ធចក្រ នឹងអាណាចក្រ ក៏លេចទៅរកវឌ្ឍនធម៌ នឹងសន្តិសុខបានដោយស្រួល ។

ឯបុគ្គលដែលត្រូវមានសង្គហធម៌សង្គ្រោះគ្នានឹងគ្នានោះ មាន ៦ ពួក, ព្រះសម្ពុទ្ធជាម្ចាស់ ទ្រង់និពន្ធជាបទព្រះគាថាប្រៀបធៀបនឹងទិសទាំង ៦ ដូច្នេះថា :–

មាតាបិតា ទិសា បុព្វា អាចរិយា ទក្ខិណា ទិសា
បុត្តទារា ទិសា បច្ឆា មិត្តាមច្ចា ច ឧត្តរា
ទាសកម្មករា ហេដ្ឋា ឧទ្ធំ សមណព្រាហ្មណា
ឯតា ទិសា នមស្សេយ្យ អលមត្តោ កុលេ គិហី ។

សេចក្ដីថា: មាតាបិតាទុកជាទិសខាងកើត, គ្រូអាចារ្យទុកជាទិសខាងត្បូង, បុត្រភរិយាទុកជាទិសខាងលិច, មិត្រសំឡាញ់ទុកជាទិសខាងជើង, ទាសកម្មករទុកជាទិសខាងក្រោម, សមណព្រាហ្មណ៍ទុកជាទិសខាងលើ, គ្រហស្ថក្នុងត្រកូលដែលមានសមត្ថភាព ចិញ្ចឹមបុត្រភរិយា ហើយនៅគ្រប់គ្រងផ្ទះសំបែង គប្បីនមស្ការនូវបុគ្គលទាំងឡាយមានមាតាបិតាជាដើមដែលទុកដូចជាទិសនោះៗ ចុះ ។

## សេចក្ដីអធិប្បាយ

មាតាបិតាទុកជាទិសខាងកើត បុត្រធីតាគប្បីមានសង្គហធម៌ប្រតិបត្តិចំពោះមាតាបិតាដោយស្ថាន ៥ យ៉ាងគឺ:

១ – កូនត្រូវតាំងចិត្តថា អាត្មាអញនេះ គឺមាតាបិតាបានចិញ្ចឹមមកហើយ អាត្មាអញត្រូវចិញ្ចឹមលោកវិញ ។

២– កូនត្រូវតាំងចិត្តថា កាលបើមាតាបិតាមានកិច្ចរវល់ នោះអាត្មាអញត្រូវបញ្ឈប់ការងាររបស់ខ្លួនទុកសិន ហើយត្រូវធ្វើកិច្ចការរវល់របស់មាតាបិតាវិញ ។

៣– កូនត្រូវតាំងចិត្តថា អាត្មាអញត្រូវដំកល់វង្សត្រកូលមាតា-បិតា ទុកឲ្យល្អមិនឲ្យវិនាស គឺថានឹងមិនញុំាងទ្រព្យសម្បត្តិរបស់មាតា-បិតាឲ្យវិនាសដោយការឥតប្រយោជន៍ នឹងសង្គ្រោះមាតាបិតាឲ្យផុតអំពីវង្សដែលមិនប្រកបដោយធម៌ ហើយឲ្យតាំងនៅក្នុងវង្សដែលប្រកបដោយ

ធម៌, និងមិនដាច់បង់នូវការកុសលទាំងឡាយ មានសលាកភត្តជាដើមដែលមាតាបិតាបានប្រព្រឹត្តធ្វើតាមគន្លងត្រូវល្អមកហើយ ។

៤– កូនត្រូវតាំងចិត្តថា អាត្មាអញនឹងតាំងគំនិតមារយាទឲ្យល្អ ឲ្យជាទីពេញចិត្តនៃមាតាបិតា ឲ្យជាមនុស្សគួរមាតាបិតាប្រគល់ទ្រព្យសម្បត្តិកេរ្តិ៍ដំណែលឲ្យ ។

៥– កូនត្រូវតាំងចិត្តថា កាលបើមាតាបិតាធ្វើកាលកិរិយាហើយ អាត្មាអញត្រូវធ្វើទក្ខិណាទាន ឧទ្ទិសចំណែកផលបុណ្យជូនដល់មាតាបិតា រឿយៗ ។

ចំណែកខាងមាតាបិតាត្រូវអនុគ្រោះបុត្រធីតាដោយស្ថាន៥យ៉ាងគឺ:

១– ហាមឃាត់កូនមិនឲ្យធ្វើកម្មអាក្រក់មានឃាត់កូនមិនឲ្យសម្លាប់សត្វ លួចទ្រព្យគេជាដើម ។

២– ឲ្យកូនដំកល់នៅក្នុងកម្មជាកុសល មានទាននិងសីលជាដើម ។

៣– ឲ្យកូនសិក្សារៀនសិល្បសាស្ត្រចំណេះវិជ្ជាដែលគួររៀនមានអក្សរនិងលេខជាដើម ។

៤– រៀបចំកូនឲ្យមានភរិយា ឬ ស្វាមីតាមសមគួរដល់ត្រកូលនិងទ្រព្យសម្បត្តិ ។

៥– ឲ្យទ្រព្យសម្បត្តិដល់កូនក្នុងសម័យពីរយ៉ាងគឺ: និច្ចសម័យ១, កាលសម័យ១, និច្ចសម័យនោះគឺ ឲ្យទ្រព្យសម្បត្តិរឿយៗ ដើម្បីឲ្យកូន

ចាយប្រើតាមការគួរ ឬ ឲ្យដើម្បីឲ្យធ្វើកុសលណាមួយ; កាលសម័យនោះ គឺឲ្យក្នុងកាលដែលបានរៀបចំឲ្យកូនមានភរិយាស្វាមីហើយ ឬ ឲ្យក្នុងកាលដែលខ្លួនជិតនឹងដល់នូវមរណភាព ។

គ្រូបាអាចារ្យទុកជាទិសខាងត្បូង សិស្សត្រូវប្រតិបត្តិដោយស្ថាន៥ យ៉ាងគឺៈ–

១– ដោយកិរិយាធ្វើនូវបច្ចុគ្គមនាការក្រោកឡើងទទួល គឺថាបើសិស្សកំពុងអង្គុយនៅក្នុងទីណាមួយ ដែលមិនមានបុគ្គលជាធំជាងគ្រូ-អាចារ្យទេ កាលបើបានឃើញគ្រូអាចារ្យមកកាន់ទីនោះ ត្រូវសិស្សក្រោកឈរឡើង, បើលោកមានគ្រឿងបរិក្ខារអ្វី ត្រូវទទួលយកមកអំពីលោកដោយអើពើ ត្រូវរកទឹកលាងជើង, រកកំណាត់ជូតជើងរួចត្រូវចាត់ចែងទីអាសនៈដើម្បីលោក, លុះលោកអង្គុយហើយ សឹមខ្លួនអង្គុយជាខាងក្រោយ ។

កាលបើលោកក្រោកលាខ្លួនទៅ ត្រូវធ្វើអនុគ្គមនាការ គឺក្រោកជូនលោកទៅ បើយ៉ាងជិតណាស់ត្រឹមមាត់ទ្វារក្រៅ ។

២– ដោយកិរិយាចូលទៅបំរើគ្រូអាចារ្យក្នុង ១ ថ្ងៃ ៣ ដងគឺ វេលាព្រឹកម្តង, ថ្ងៃត្រង់ម្តង, ល្ងាចម្តង ។

៣– ដោយកិរិយាជឿស្តាប់ពាក្យទូន្មានគ្រូអាចារ្យ ដែលលោកពោលទូន្មានប្រៀនប្រដៅដោយល្អ ។

៤- ដោយការបំរើតូចៗ មានឲ្យឈើស្ទន់នឹងទឹកលុបមុខជាដើម ។

៥- ដោយកិរិយារៀននូវសិល្បសាស្ត្រ ចំណេះវិជ្ជាអំពីគ្រូអាចារ្យ ដោយគោរព គឺរៀនម្តងៗ តាមសមគួរដល់កំលាំងប្រាជ្ញានៃខ្លួនហើយ ស្វាធ្យាយទន្ទេញដកបដល់ចាំ ដល់ចូលចិត្ត ។

ចំណែកគ្រូអាចារ្យត្រូវអនុគ្រោះសិស្សដោយស្ថាន ៥ យ៉ាង គឺ:

១- ខ្លួនបង្រៀនប្រដៅសិស្សដោយល្អ គឺខ្លួនបង្រៀនប្រដៅឲ្យសិស្សចេះរៀបចំកិរិយាបថទាំង ៤ គឺដេក, ដើរ, ឈរ, អង្គុយ ឲ្យរៀបរយ ព្រមទាំងប្រដៅមិនឲ្យសេពគប់នឹងបាបមិត្រឲ្យសេពគប់តែនឹងកល្យាណមិត្ត ។

២- បង្ហាត់បង្រៀនសិស្សដោយល្អ គឺបង្ហាត់បង្រៀនដោយត្រូវតាមអត្ថនិងព្យញ្ជនៈ នឹងរបៀបពាក្យរបៀបសេចក្តីឲ្យសិស្សចាំចូលត្រឹមចិត្ត ។

៣- បង្ហាញសិល្បសាស្ត្រចំណេះវិជ្ជាដល់សិស្ស ដោយមិនលាក់ទុក គឺថាបើខ្លួនចេះប៉ុន្មាន ចង់ឲ្យសិស្សចេះប៉ុណ្ណោះដែរ ។

៤- ពោលពាក្យលើកសរសើរសិស្ស ដែលមានសិល្បសាស្ត្រចំណេះវិជ្ជា នឹងកិរិយាមារយាទល្អពិតនោះ ឲ្យច្បាស់ប្រាកដដល់មិត្រនឹងអាមាត្យ ។

៥– ធ្វើនូវសេចក្តីការពារគ្រូសិស្ស ក្នុងទិសទាំងឡាយ គឺថាឲ្យសិស្សរៀនសិល្បសាស្ត្រចំណេះវិជ្ជា មិនឲ្យទើសទាល់ក្នុងវេលាដែលសិស្សនៅក្នុងទិសនោះៗ ។

ភរិយាទុកជាទិសខាងលិច ស្វាមីគប្បីអនុគ្រោះដោយស្ថាន ៥ យ៉ាង គឺ:

១– ដោយសេចក្តីរាប់អានដោយសំដីដ៏ទន់ផ្អែមទៅរកភរិយា ។

២– ដោយកិរិយាមិនបៀតបៀន មិនមើលងាយភរិយាដូចទាស-កម្មករ ។

៣– ដោយកិរិយាមិនប្រព្រឹត្តកន្លងចិត្តភរិយា ។

៤– ដោយកិរិយាប្រគល់នូវឥស្សរិយៈ គឺការៈជាធំក្នុងការចាត់ចែងម្ហូបចំណីឲ្យជាប់មុខទៅភរិយា ។

៥– ដោយកិរិយាផ្តល់ផ្គង់នូវគ្រឿងប្រដាប់ដល់ភរិយា តាមសមគួរដល់សម្បត្តិរបស់ខ្លួន ។

ចំណែកភរិយាត្រូវប្រតិបត្តិស្វាមីដោយស្ថាន ៥ យ៉ាងគឺ:

១– ចាត់ចែងការងារមានការចំអិននូវអាហារជាដើម ដោយល្អិតល្អន់,

២– សង្គ្រោះដល់ជនជាញាតិរបស់ស្វាមី និងញាតិរបស់ខ្លួនដោយស្មោះស្មើ ។

៣– ចេះថែទាំទុកដាក់នូវទ្រព្យសម្បត្តិ ដែលស្វាមីរកបានមកហើយ ។

៤– មិនប្រព្រឹត្តកន្លងចិត្តស្វាមី ។

៥– ជាស្រីឈ្លាសប្រសប់ក្នុងកិច្ចការទាំងឡាយ មានការចាត់ចែងនូវបរិវារជនជាដើម ឥតខ្ជិលច្រអូសក្នុងកិច្ចការទាំងពួង ហើយអាចញុំាងកិច្ចទាំងនោះឲ្យសម្រេចបាន ។

**មិត្រសំឡាញ់ទុកជាទិសខាងជើង** កុលបុត្រគប្បីទំនុកបម្រុងដោយស្ថាន ៥ យ៉ាង គឺ:

១– ដោយកិរិយាឲ្យទ្រព្យរបស់ដែលគួរឲ្យដល់មិត្រ ។

២– ដោយកិរិយាពោលពាក្យពីរោះទៅរកមិត្រ ។

៣– ដោយកិរិយាប្រព្រឹត្តិធ្វើនូវប្រយោជន៍ឲ្យកើតដល់មិត្រ ។

៤– ដោយការៈជាអ្នកមានខ្លួននឹងចិត្តស្មើដោយមិត្រ ។

៥– ដោយការៈមិនក្លែងពោលឲ្យឃ្លាតចាកសេចក្ដីពិតដល់មិត្រ ។

ចំណែកខាងមិត្រសំឡាញ់ត្រូវអនុគ្រោះកុលបុត្រ ដោយស្ថាន ៥ យ៉ាង គឺ:

១– ជួយរក្សាមិត្រដែលបានជាភ្លាំងភ្លាត់ធ្វេសប្រហែស ។

២– ជួយថែរក្សាទ្រព្យសម្បត្តិរបស់មិត្រដែលមិត្របានជាភ្លាំងភ្លាត់ធ្វេសប្រហែស ។

៣– កាលបើមិត្រមានសេចក្ដីភិតភ័យ ក៏អាចជាទីពឹងអាស្រ័យដល់មិត្របាន ។

៤- មិនលះបង់ចោលមិត្រក្នុងកាលដែលមិត្រមានការក្រ ។

៥- ស្រឡាញ់រាប់អានកូនចៅផៅពង្សរបស់មិត្រ ។

ទាសកម្មករទុកជាទិសខាងក្រោម ចៅហ្វាយនាយគប្បីទំនុកបំរុងដោយស្ថាន ៥ យ៉ាង គឺ:

១- ដោយកិរិយាចាត់ចែងនូវការងារឲ្យធ្វើតាមសមគួរដល់កំលាំងនៃទាសកម្មករ គឺថាដាក់ការងារឲ្យធ្វើតាមការសម្រាប់ប្រុសស្រីចាស់ក្មេង ។

២- ដោយកិរិយាធ្វើនូវភត្តាហារនឹងឈ្នួល ឬ បំណាច់រង្វាន់តាមសមគួរដល់ខំនងដែលត្រូវឲ្យ ។

៣- ដោយកិរិយាព្យាបាលរក្សាថែទាំទាសកម្មករ ក្នុងកាលដែលមានជម្ងឺ ហើយមិនបៀតបៀនឲ្យធ្វើការងារអ្វីឡើយ ។

៤- ដោយកិរិយាចែករំលែកនូវរបស់ដែលមានរសឆ្ងាញ់ត្រូវការៈឲ្យទាសកម្មករបរិភោគ ។

៥- ដោយកិរិយាបើកឱកាសឲ្យឈប់ធ្វើការក្នុងនិច្ចសម័យ គឺថាកាលបើទាសកម្មករធ្វើការនឿយហត់ពេញ ១ ថ្ងៃ ក៏ឲ្យឈប់សម្រាកកំលាំងខ្លះ ។ ឲ្យឈប់ធ្វើការក្នុងកាលសម័យ គឺថាបើដល់កំណត់ថ្ងៃនក្ខត្តឫក្សមានថ្ងៃចូលឆ្នាំជាដើម ក៏បើកឲ្យឈប់ធ្វើការ ។

ចំណែកខាងឯបាវព្រាវនឹងមនុស្សដែលធ្វើការឈ្នួល ត្រូវយកចិត្តទុកដាក់បំពេញបំបានចៅហ្វាយនាយរបស់ខ្លួនដោយស្ថាន ៥ យ៉ាង គឺ:

១– ក្រោកឡើងធ្វើការងារមុនចៅហ្វាយនាយ ។

២– ឈប់ធ្វើការងារក្រោយចៅហ្វាយនាយ ។

៣– មិនលួចទ្រព្យរបស់ចៅហ្វាយនាយ យកតែរបស់ដែលចៅហ្វាយនាយឲ្យ ។

៤. ធ្វើការងាររបស់ចៅហ្វាយនាយ ដោយពិចិត្រពិច័យល្អិតល្អន់អស់ពីចិត្ត ឥតមានគិតកាញ់គ្នេរ ។

៥- យកការងាររបស់ចៅហ្វាយនាយ ទៅពោលសរសើរគុណទីនោះៗ ។

## សមណព្រាហ្មណ៍ទុកជាទិសខាងលើ

កុលបុត្រជាគ្រហស្ថគប្បីប្រតិបត្តិផ្គត់ផ្គង់ដោយស្ថាន ៥ យ៉ាង គឺ:

១– ដោយកាយកម្មប្រកបដោយមេត្តា គឺថាធ្វើនូវកិច្ចដោយកាយ មានទៅនិមន្តលោកនឹងទទួលយកនូវតម្រងទឹក ទៅត្រងទឹកប្រគេនលោក នឹងគក់ប្រចាប់ជាដើម ដោយសេចក្តីរាប់អានដ៏ស្មោះត្រង់ ។

២ ដោយវចីកម្មប្រកបដោយមេត្តា គឺថាធ្វើនូវកិច្ចដោយវាចា មានពោលពាក្យដាស់តឿនអ្នកឯទៀត ឲ្យធ្វើទានដល់សមណព្រាហ្មណ៍នឹងបន្លឺនូវសេចក្តីសាធុការគុណកាលដែលស្តាប់ធម៌ទេសនាចប់ នឹងធ្វើនូវបដិសណ្ឋារៈដោយសំដីកក់ទាក់ជាដើម ដោយសេចក្តីរាប់អានដ៏ស្មោះត្រង់ ។

៣– ដោយមនោកម្មប្រកបដោយមេត្តា គឺថាធ្វើនូវកិច្ចដោយចិត្ត មានគិតថា ព្រះថេរៈទាំងឡាយដែលលោកតែងនិមន្តមកកាន់ត្រកូលរបស់យើង សូមឲ្យលោកបានសេចក្តីសុខសប្បាយជាដើម ដោយសេចក្តីរាប់អានដ៏ស្មោះត្រង់អស់ពីចិត្ត ។

៤– ដោយការៈជាអ្នកមានទ្វារផ្ទះមិនបិទ គឺថាជាអ្នកឧស្សាហ៍ធ្វើទានដល់សមណព្រាហ្មណ៍ កាលបើឃើញសមណព្រាហ្មណ៍មកដល់ហើយ ក៏ឲ្យទានដោយមិនពោលត្អូញត្អែរចំពោះរបស់ដែលមាននោះថាជាគ្មានវិញឡើយ ។

៥– ដោយកិរិយាឲ្យនូវអាមិសៈ គឺឲ្យនូវខាទនីយភោជនីយាហារដល់សមណព្រាហ្មណ៍ ។

ចំណែកខាងសមណព្រាហ្មណ៍ ត្រូវអនុគ្រោះកុលបុត្រដោយស្ថាន ៦ យ៉ាង គឺ:

១– ហាមឃាត់កុលបុត្រមិនឲ្យធ្វើកម្មអាក្រក់ មានឃាត់មិនឲ្យសំឡាប់សត្វនឹងមិនឲ្យលួចទ្រព្យគេជាដើម ។

២– ឲ្យកុលបុត្រដំកល់នៅក្នុងកុសល មានទាននិងសីលជាដើម ។

៣– អនុគ្រោះកុលបុត្រដោយកល្យាណចិត្ត គឺតាំងចិត្តផ្សាយមេត្តាធម៌ដល់កុលបុត្រទាំងឡាយថា ឲ្យបានសេចក្តីសុខ កុំបីមានទុក្ខ, សោក, រោគ, ភ័យអ្វីឡើយ ។

៤– ឲ្យកុលបុត្របានស្តាប់នូវធម៌ដែលមិនធ្លាប់បានស្តាប់ ។

៥– ញុំាងធម៌ដែលកុលបុត្រធ្លាប់បានស្តាប់ហើយ ឲ្យផូរផង់ល្អ គឺថាប្រាប់ពន្យល់សេចក្តីនៃធម៌នោះ ឲ្យច្បាស់លាស់ប្រាកដឡើង ត្រាតែកុលបុត្រនោះលែងមានសេចក្តីសង្ស័យ ។

៦– ប្រាប់ផ្លូវសួគ៌ដល់កុលបុត្រ មានប្រាប់ឲ្យដឹងដូច្នេះថា បុគ្គលដែលបានទៅកើតក្នុងឋានសួគ៌នោះ ព្រោះអំណាចនៃកុសលមានសីល ៥ នឹងកុសលកម្មបថ ១០ ជាដើម ។

កាលបើបុគ្គលទាំង ៦ ពួកគឺ: មាតាបិតានឹងបុត្រធីតា គ្រូបាអាចារ្យនឹងសិស្សានុសិស្ស, ភរិយានឹងស្វាមី, មិត្រសំឡាញ់នឹងកុលបុត្រ, ទាស-កម្មករនឹងចៅហ្វាយនាយ, សមណព្រាហ្មណ៍នឹងកុលបុត្រ បានប្រព្រឹត្តត្រូវតាមស្ថានដែលខ្លួនត្រូវប្រតិបត្តិ ត្រូវអនុគ្រោះទៅវិញទៅមកដូច្នេះហើយ បុគ្គលទាំងនោះ ឈ្មោះថាបិទបាំងនូវភ័យអន្តរាយ មិនឲ្យកើតឡើងបាន ជាបុគ្គលមានកេរ្តិ៍ឈ្មោះល្អក្នុងលោកទាំងពីរ គឺលោកនេះនឹងលោកខាងមុខ រមែងបាននូវកេរ្តិ៍ឈ្មោះយសសក្តិ ចំរើនដោយសុខភាពអនាម័យដ៏ល្អ ។

សង្គហធម៌ទាំង ៤ នេះ បើបុគ្គលណាបានប្រតិបត្តិដោយប្រពៃហើយ កេរ្តិ៍ឈ្មោះរបស់បុគ្គលនោះនឹងផុលផុសឡើងក្នុងលោក ផ្សាយនូវក្លិនពិ-ដោរឈ្ងុយឈ្ងប់គ្រប់ទិស ជនភាគច្រើនតែងដើរត្រសងស្រង់តាមក្លិនចូលទៅទទួលស្គាល់បុគ្គលនោះជានាយចៅហ្វាយជាមិត្រសំឡាញ់ ប្រៀប

ដូចបុប្ផជាតិដែលមានក្លិនក្រអូបឆើត ជាទីកើតតម្រេកនៃភមរជាតិទាំងឡាយ មានកន្ទុំជាដើមដូច្នោះដែរ ។

ន័យមួយទៀតព្រះសម្ពុទ្ធជាម្ចាស់ទ្រង់ត្រាស់សំដែងថា:

យស្មា ច សង្គហា ឯតេ សមបេក្ខន្តិ បណ្ឌិតា
តស្មា មហត្តំ បប្បោន្តិ បាសំសា ច ភវន្តិ តេ ។

សេចក្តីថា អ្នកប្រាជ្ញទាំងឡាយ លោកបានប្រព្រឹត្តនូវសង្គ-ហធម៌ទាំង ៤ នេះដោយប្រពៃ ព្រោះហេតុនោះបានជាលោកបានដល់នូវភាវៈជាធំ ព្រមទាំងបាននូវសេចក្តីសរសើរអំពីប្រជុំជនផងទៀត ។

សំដែងមកអំពីសង្គហធម៌ ក៏សន្មតថាចប់ដោយសង្ខេបតែប៉ុណ្ណេះ ។

ដោយអានុភាពនៃធម្មទេសនា សូមទេវតាទាំងមួយហ្មឺនលោកធាតុ រក្សាព្រះប្រិយមហាក្សត្រកម្ពុជាធិបតី ព្រមទាំងព្រះរាជវង្សានុវង្ស សូមទ្រង់ប្រសិទ្ធដោយចតុរពិធពរ រុងរឿងដោយសតិបញ្ញា បរិហាររបនាកម្ពុជរដ្ឋឲ្យដល់នូវឧត្តមគតិ ដោយមុហុត្តកាល ។

ទាំងសូមពុទ្ធបរិស័ទទាំងឡាយគ្រប់ជាន់ ដែលបានប្រតិបត្តិតាមសាសនវិធី ក្រោមអធិបតេយ្យនៃព្រះសម្មាសម្ពុទ្ធ ឲ្យចំរើនដោយសុខភាព អនាម័យដ៏ល្អ ដើម្បីជាពលរដ្ឋប្រកបកិច្ចសាសនា ក្លាហាន បានមគ្គាភិសម័យទៅហោង ។

ចប់

---

# ប្រវត្តិព្រះអភិធម្ម

## យុនសិរីមេធី ស្រី-អ៊ួ ក្រុមជំនុំព្រះត្រៃបិដក

## រៀបរៀង

---

ពាក្យថា "អភិធម្ម" ប្រែថា "ធម៌ដ៏ប្រសើរ" ឬប្រែថា "ធម៌ជាធំ ក្រៃលែងជាងធម៌ទាំងឡាយ" មាន ៧ គម្ពីរ គឺ:

១– ធម្មសង្គណី,

២– វិភង្គ,

៣– ធាតុកថា,

៤– បុគ្គលប្បញ្ញត្តិ,

៥– កថាវត្ថុ,

៦– យមកៈ,

៧- បដ្ឋាន ឬ មហាបដ្ឋាន ។

ទាំង ៧ គម្ពីរនេះ ហៅថា "អភិធម្ម" ។

ពាក្យថា "អភិធម្មសង្គហៈ" គឺការប្រមូលសេចក្ដីនៃព្រះអភិធម្មមកប្រមូលទុកដោយបំព្រួញ ។

ពាក្យថា "បរមត្ថ" គឺសេចក្ដីដ៏ក្រៃលែងក្នុងគម្ពីរព្រះអភិធម្មនោះ ។ ព្រះអភិធម្មនោះ ព្រះសម្មាសម្ពុទ្ធទ្រង់សំដែងចំពោះពួកទេវតា ក្នុងតាវត្តិង្សទេវលោក មានទេវបុត្រមួយអង្គធ្លាប់ជាពុទ្ធមាតាជាប្រធាន ដូចមានបាលីអាគតដ្ឋានថា :-

ឆាវិប្បត្តកមូលម្ហិ    បណ្ឌុកម្ពលនាមកេ
សិលាសនេ សន្និសិន្នោ អាទិច្ចោវ យុគន្ធរេ
មាតរំ បមុខំ កត្វា    តស្ស បញ្ញាយ តេជសា
អភិធម្មកថាមគ្គំ    ទេវានំ សម្បវត្តយិ ។

ប្រែថា: "ព្រះបរមសាស្ដាទ្រង់គង់លើសិលាសនៈឈ្មោះបណ្ឌុកម្ពល ក្រោមដើមប៉ារិច្ឆត្តកព្រឹក្ស ទ្រង់មានព្រះធញ្ញណរង្សីដ៏រុងរឿងដូចព្រះអាទិត្យស្ថិតនៅលើកំពូលភ្នំយុគន្ធរ ទ្រង់សំដែងផ្លូវកថាមគ្គ គឺព្រះអភិធម្មទេវតាមានសន្តុស្សិតទេវបុត្រជាពុទ្ធមាតាជាប្រធាន ដោយតេជានុភាពដល់ពុទ្ធនៃបញ្ញាបារមីនោះ" ។

ព្រះមហាសារីបុត្របានទទួលស្ដាប់អំពីព្រះឧស្ឋនៃព្រះសាស្ដា ជាដំបូង ក្នុងព្រៃចន្ទន៍នាហិមវន្តប្បទេសក្បែរស្រះអនោតត្ត ក្នុងឱកាសដែលព្រះអង្គមកសោយព្រះក្រយាហារ ។ ព្រះសារីបុត្របាននាំទៅបរើកក្នុងទីនោះហើយលោកនាំមកសំដែងដល់ភិក្ខុចំនួន ៥០០ រូបជាដំបូង ទើបមានការសិក្សាសូត្ររៀនជាប់តៗ គ្នាមក ។

ព្រះអភិធម្មជាពុទ្ធវចនៈដោយពិត ដូចមានបាលីក្នុងគម្ពីរអដ្ឋសាលិនីថា: អភិធម្មោ នាមេស សព្វញ្ញុតញ្ញាណំ យេវ វិសយោ ន អញ្ញេសំ វិសយោ "ព្រះអភិធម្មនេះជាវិស័យនៃព្រះសព្វញ្ញុតញ្ញាណតែម្យ៉ាង មិនមែនជាវិស័យនៃជនដទៃទឹងសំដែងបានទេ" ។

ការសិក្សាព្រះអភិធម្ម មានប្រយោជន៍ធំទូលាយណាស់ ព្រោះជាមេបទ ឬ ជាគោលនៃធម៌ទាំងឡាយទូទៅដូចមានពាក្យជាដើមថាៈ បណ្ដាធម៌ទាំង ៨៤,០០០ ព្រះធម្មក្ខន្ធ កាលបើរួបរួមចុះប្រភេទនៃតិកមាតិកា បានដល់ធម៌ ៣ ប្រការគឺកុសលធម៌, អកុសលធម៌, អព្យាកតធម៌, ហើយការសិក្សាព្រះអភិធម្មនោះនឹងមានផលច្រើន ទៅជាអ្នកមានបញ្ញាតាំងអំពីជាតិនេះ នឹងបានជាបញ្ញាបារមីទៅជាតិខាងមុខទៀត ទាំងជាហេតុឲ្យប្រតិបត្តិមគ្គទាំង ៨ ប្រការ មិនខុសពាកផ្លូវផង ។

ចប់

យោព្វនរូបសម្បន្នោ វិសាលកុលសម្ភវោ
វិជ្ជាហីនោ ន សោភតិ និគន្ធា ឥវកឹសុកា
បុរសនៅក្មេងរូបល្អឆើត ទាំងបានមកកើតត្រកូលខ្ពស់
តែហីនវិជ្ជាក៏គ្មានយស ឥតរុងរឿងស្រស់ក្នុងសង្គម ។
ដូចជាផ្កាចារក្រហមប្រាល ត្រកាលតែពណ៌មិនឧត្ដម
ព្រោះគ្មានក្លិនក្លែបក្លួមនោរម្យ នេះបំជាផ្កាឥតប្រយោជន៍ ។

ស្រី - អ៊ូ